ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករធានារ៉ាប់រងកម្ពុជា
លេខ...០០១..........ន.ធ.ក. / សណរ

# សេចក្ដីណែនាំ
# ស្ដីពី
# ការបណ្ដុះបណ្ដាលវិជ្ជាជីវៈជើងសាធានារ៉ាប់រង

ក្នុងគោលបំណងបង្កើនគុណភាពវិជ្ជាជីវៈជើងសាធានារ៉ាប់រង អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្ដីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការធានារ៉ាប់រងខ្នាតតូច, ប្រកាសលេខ ០៥៩ អ.ស.ហ.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង, គោលការណ៍ណែនាំលេខ ០៤៤ ន.ធ.ក./សណន ចុះថ្ងៃទី១០ ខែធ្នូ គ.ស.២០២៤ ស្ដីពីក្រមសីលធម៌បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង, ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធការធានារ៉ាប់រង និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**) សូមចេញសេចក្ដីណែនាំស្ដីពី "**ការបណ្ដុះបណ្ដាលវិជ្ជាជីវៈជើងសាធានារ៉ាប់រង**" ដូចខាងក្រោម៖

## ក. វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈជើងសាធានារ៉ាប់រង

### ១. កម្មវិធីសិក្សា

កម្មវិធីសិក្សាត្រូវរៀបចំឡើងដោយមាន ៦ (ប្រាំមួយ) មុខវិជ្ជា និងរយៈពេលសិក្សាអប្បបរមាដូចខាងក្រោម៖

| មុខវិជ្ជាសិក្សា | មាតិកាគោល | រយៈពេលសិក្សា |
|---|---|---|
| **គោលការណ៍គ្រឹះនៃការធានារ៉ាប់រង** | - ការផ្ដល់ព័ត៌មានដោយស្មោះត្រង់បំផុត<br>- ទំនាក់ទំនងអត្ថប្រយោជន៍ដែលអាចធានាបាន<br>- ការផ្ដល់សំណងធានារ៉ាប់រង | ១២០ នាទី |



អគារលេខ ១៦៨ F (ជាន់ទី៦) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Building # 168 F (6th Floor), St. 598, Sangkat Chraing Chamres 1,
Khan Russey Keo, Phnom Penh, Cambodia.
071 258 0896
gad@irc.gov.kh
www.irc.gov.kh

| | | |
|---|---|---|
| | - សិទ្ធិទាមទារសំណងធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងពីភាគីទីបីដែលធ្វើឱ្យខូចខាតដល់អ្នកត្រូវបានធានារ៉ាប់រង<br>- ការរួមគ្នាធ្វើសំណងធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រង<br>- មូលហេតុដោយផ្ទាល់បំផុតដែលនាំឱ្យមានសំណងធានារ៉ាប់រង | |
| **ទិដ្ឋភាពទូទៅនៃការធានារ៉ាប់រង** | - ទីផ្សារធានារ៉ាប់រង<br>- វប្បធម៌ និងបទដ្ឋានសង្គមក្នុងទីផ្សារធានារ៉ាប់រង | ១៥០ នាទី |
| **ផលិតផលធានារ៉ាប់រង** | - *ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិត*<br>• ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតមានកាលកំណត់<br>• ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតមួយជីវិតកាល<br>• ប្រភេទផលិតផលធានារ៉ាប់រងទាយជ្ជទាន<br>• ប្រភេទផលិតផលធានារ៉ាប់រងធនលាភ<br>• ប្រភេទផលិតផលធានារ៉ាប់រងផ្សេងទៀត (ប្រសិនបើមាន)<br>- *ប្រភេទផលិតផលធានារ៉ាប់រងទូទៅ*<br>• ប្រភេទផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល<br>• ប្រភេទផលិតផលធានារ៉ាប់រងសុខភាព<br>• ប្រភេទផលិតផលធានារ៉ាប់រងយានយន្ត<br>• ប្រភេទផលិតផលធានារ៉ាប់រងលើទ្រព្យសម្បត្តិ<br>• ប្រភេទផលិតផលធានារ៉ាប់រងលើដំណាំ<br>• ប្រភេទផលិតផលធានារ៉ាប់រងលើសត្វចិញ្ចឹម<br>• ប្រភេទផលិតផលធានារ៉ាប់រងដឹកជញ្ជូន<br>• ប្រភេទផលិតផលធានារ៉ាប់រងវិស្វកម្ម<br>• ប្រភេទផលិតផលធានារ៉ាប់រងផ្សេងទៀត | ៦០ នាទី សម្រាប់ប្រភេទផលិតផលធានា-រ៉ាប់រងនីមួយៗ |
| **វិជ្ជាជីវៈជើងសាធានារ៉ាប់រង** | - គោលបំណង និងសេចក្តីសង្ខេបនៃការសិក្សា<br>- តួនាទី និងភារកិច្ចរបស់ជើងសាធានារ៉ាប់រង | ២១០ នាទី |

| | | |
|---|---|---|
| | - តួនាទីរបស់ជើងសាជានាវ៉ាប់រងក្នុងការបម្រើសេវាកម្មដល់អតិថិជន<br>- វិធីសាស្រ្តក្នុងការគ្រប់គ្រងហានិភ័យរបស់ជើងសាជានាវ៉ាប់រង<br>- វិធីសាស្រ្តក្នុងការជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងរបស់ជើងសាធានារ៉ាប់រង<br>- ការអនុវត្តដែលជើងសាធានារ៉ាប់រងអាច និងមិនអាចធ្វើបាន<br>- ជើងសាធានារ៉ាប់រងនៅក្នុងនីតិវិធីនៃការទាមទារសំណងធានារ៉ាប់រង<br>- ការការពារការក្លែងបន្លំធានារ៉ាប់រង | |
| **ច្បាប់ និងបទប្បញ្ញត្តិធានារ៉ាប់រង** | - ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យធានារ៉ាប់រង<br>- តើអ្វីទៅជាក្រុមហ៊ុនជើងសាធានារ៉ាប់រង ?<br>- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ៩០ នាទី |
| **ក្រមសីលធម៌បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង** | - សញ្ញាណទូទៅ<br>- គោលការណ៍ប្រតិបត្តិវិជ្ជាជីវៈ<br>• សមត្ថភាពវិជ្ជាជីវៈ<br>• សុចរិតភាព និងភាពស្មោះត្រង់<br>• ការទទួលខុសត្រូវប្រកបដោយវិជ្ជាជីវៈ<br>• ការប្រតិបត្តិវិជ្ជាជីវៈ<br>• ការសម្ងាត់វិជ្ជាជីវៈ<br>• ទំនាស់ផលប្រយោជន៍<br>• ការបន្តបម្រើអតិថិជនបន្ទាប់ពីការចេញបណ្ណសន្យារ៉ាប់រង<br>- យន្តការតាមដាន និងត្រួតពិនិត្យ<br>- វិធានការវិន័យនៃក្រមសីលធម៌ | ៩០ នាទី |

បុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈជើងសាជានាវ៉ាប់រងអាយុជីវិត ត្រូវចូលរួមវគ្គ-បណ្តុះបណ្តាលតាមកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រងអាយុជីវិតដែលមានមុខវិជ្ជាៈ គោលការណ៍គ្រឹះនៃការធានារ៉ាប់រង, ទិដ្ឋភាពទូទៅនៃការធានារ៉ាប់រង, ផលិតផលធានារ៉ាប់រងអាយុជីវិត, វិជ្ជាជីវៈជើងសាជានាវ៉ាប់រង, ច្បាប់និងបទប្បញ្ញត្តិធានារ៉ាប់រង និងក្រមសីលធម៌បុគ្គលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង។

បុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈជើងសាជានាវ៉ាប់រងទូទៅ ត្រូវចូលរួមវគ្គបណ្តុះ-បណ្តាលតាមកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រងទូទៅដែលមានមុខវិជ្ជាៈ គោលការណ៍គ្រឹះនៃការធានារ៉ាប់រង, ទិដ្ឋភាពទូទៅនៃការធានារ៉ាប់រង, ផលិតផលធានារ៉ាប់រងទូទៅ, វិជ្ជាជីវៈជើងសាជានាវ៉ាប់រង, ច្បាប់និងបទប្បញ្ញត្តិធានារ៉ាប់រង និងក្រមសីលធម៌បុគ្គលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង។

បុគ្គលទាំងឡាយណាដែលបានចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រងទូទៅ ឬអាយុជីវិត អាចប្រកបវិជ្ជាជីវៈជើងសាជានាវ៉ាប់រងខ្នាតតូចទូទៅ ឬអាយុជីវិតបាន។

**២. ឯកសារ និងវិធីសាស្ត្របង្រៀន**

សមាគមជើងសាជានាវ៉ាប់រងកម្ពុជា ត្រូវរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល វិធីសាស្ត្របង្រៀនលើមុខវិជ្ជាសិក្សាដូចមានកំណត់ក្នុងកម្មវិធីសិក្សាខាងលើ និងគំរូវិញ្ញាបនបត្រវិជ្ជាជីវៈជើងសាជានាវ៉ាប់រង និងត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** មុននឹងផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង។

**៣. ការផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង**

សមាគមជើងសាជានាវ៉ាប់រងកម្ពុជា ត្រូវទទួលខុសត្រូវរៀបចំផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង ដោយចាត់ចែងរៀបចំឱ្យមានគ្រូបណ្តុះបណ្តាលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដោយត្រូវមានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធក្នុងវិស័យធានារ៉ាប់រងយ៉ាងតិច ៣ (បី) ឆ្នាំ។

រាល់ការតែងតាំង ឬផ្លាស់ប្តូរគ្រូបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង សមាគមជើងសាជានាវ៉ាប់រងកម្ពុជា ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់គុណវុឌ្ឍិដូចខាងក្រោមៈ

- ប្រវត្តិរូបសង្ខេប
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ជាច្បាប់ថតចម្លង)
- សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ (ជាច្បាប់ថតចម្លង)
- លិខិតបញ្ជាក់អំពីបទពិសោធន៍ការងារចេញដោយសមាគមជើងសាជានាវ៉ាប់រងកម្ពុជា។

**៤. ការប្រឡង និងវិញ្ញាបនបត្រវិជ្ជាជីវៈជើងសាជានាវ៉ាប់រង**

វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រងត្រូវបញ្ចប់ដោយការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាល។ ចំពោះសិក្ខាកាមដែលចាត់ទុកថាប្រឡងជាប់ ត្រូវមានកម្រិតពិន្ទុចាប់ពី ៦០ (ហុកសិប) ភាគរយ នៃពិន្ទុសរុបឡើងទៅ។

វិញ្ញាបនបត្រវិជ្ជាជីវៈជើងសាជានាវ៉ាប់រង ត្រូវបានផ្តល់ជូនដល់សិក្ខាកាមដែលបានប្រឡងជាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាជានាវ៉ាប់រង។ វិញ្ញាបនបត្រវិជ្ជាជីវៈជើងសាជានាវ៉ាប់រងនេះ ត្រូវចុះហត្ថលេខាដោយសមាគមជើងសាជានាវ៉ាប់រងកម្ពុជា។

## ខ. ការបណ្តុះបណ្តាលអំពីលក្ខណៈនៃផលិតផលធានារ៉ាប់រង

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ដែលមានបំណងចាប់ដៃគូផ្តល់សេវាជើងសាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយ ត្រូវបណ្តុះបណ្តាលបុគ្គលិកក្រុមហ៊ុនជើងសាធានារ៉ាប់រងអំពីលក្ខណៈនៃផលិតផលធានារ៉ាប់រងទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រងដែលជាដៃគូនោះ។

## គ. វគ្គបណ្តុះបណ្តាលលើការអភិវឌ្ឍវិជ្ជាជីវៈជើងសាធានារ៉ាប់រង

បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាធានារ៉ាប់រង ត្រូវបន្តចូលរួមវគ្គបណ្តុះបណ្តាលលើការអភិវឌ្ឍវិជ្ជាជីវៈជើងសាធានារ៉ាប់រងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ោងក្នុងមួយឆ្នាំ។ កម្មវិធីសិក្សាវគ្គបណ្តុះបណ្តាលលើការអភិវឌ្ឍវិជ្ជាជីវៈជើងសាធានារ៉ាប់រងនឹងត្រូវកំណត់ដោយសមាគមជើងសាធានារ៉ាប់រងកម្ពុជា។

## ឃ. ការអនុវត្ត

សមាគមជើងសាធានារ៉ាប់រងកម្ពុជា ក្រុមហ៊ុនជើងសាធានារ៉ាប់រង និងបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងទាំងឡាយណាដែលមិនគោរពតាមសេចក្តីណែនាំនេះ នឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ង. សុពលភាពនៃសេចក្តីណែនាំ

ទទួលបានសេចក្តីណែនាំនេះ សមាគមជើងសាធានារ៉ាប់រងកម្ពុជា ក្រុមហ៊ុនជើងសាធានារ៉ាប់រង និងបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមករា គ.ស.២០២៦

**អគ្គនាយក**
**និយ័តករធានារ៉ាប់រងកម្ពុជា**

ប៊ូ ច័ន្ទភិរូ

**ចម្លងជូន៖**

- អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចចំណុច ឃ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ